លេខ ២១ ចេញផ្សាយថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែកុម្ភៈ ឆ្នាំ២០២៣

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## កិច្ចពិភាក្សាលើទិដ្ឋភាពបច្ចេកទេសពន្ធដារ និងបរធនបាលកិច្ច

នាព្រឹកថ្ងៃព្រហស្បតិ៍ ១២កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៣ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ក្រុមការងារ **ន.ប.ធ.** បានជួបពិភាក្សាលើទិដ្ឋភាពបច្ចេកទេសពន្ធដារ និងបរធនបាលកិច្ច ជាមួយក្រុមការងារអគ្គនាយកដ្ឋានពន្ធដារ ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តក្នុងការកំណត់ពន្ធពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ចនៅកម្ពុជា។



រូបភាពកិច្ចពិភាក្សាលើទិដ្ឋភាពបច្ចេកទេសពន្ធដារ និងបរធនបាលកិច្ច។

## មាតិកា


- កិច្ចពិភាក្សាលើទិដ្ឋភាពបច្ចេកទេសពន្ធដារ និងបរធនបាលកិច្ច ទំព័រទី១
- កិច្ចពិភាក្សាជាមួយក្រុមហ៊ុន Shepherd TechFin ទំព័រទី២
- ថ្នាក់ដឹកនាំ **ន.ប.ធ.** បានពាំនាំយកថវិកាដែលជាការបរិច្ចាគ ប្រគល់ជូនមូលនិធិគន្ធបុប្ផាកម្ពុជា ទំព័រទី២
- កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកាឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) ទំព័រទី៣
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែមករា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៣ ទំព័រទី៣
- កិច្ចប្រជុំពិភាក្សាផ្ទៃក្នុងអំពីការធ្វើបច្ចុប្បន្នភាពឯកសារគោលការណ៍ប្រតិបត្តិទូទៅផ្នែកឥណទាន (GoG) និងនីតិវិធីប្រតិបត្តិមូលនិធិធានាឥណទាន (CGF account) ទំព័រទី៤

  កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទំព័រទី៤
- កម្មវិធីពិធីផ្សព្វផ្សាយ "ចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០៣០" ទំព័រទី៤

  កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករ ទំព័រទី៥
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" ទំព័រទី៥
- កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារឆ្នាំ២០២២ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ** ទំព័រទី៦
- សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ទំព័រទី៧
- កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២២ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ បូក២ (PFM-TWG) ទំព័រទី៧
- សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ទំព័រទី៨
- កិច្ចប្រជុំផ្សព្វផ្សាយសារាចរស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ និងផ្សព្វផ្សាយគម្រោងថវិការបស់ **ន.ប.ធ.** ឆ្នាំ២០២៣ ទំព័រទី៨
- វគ្គបណ្តុះបណ្តាលស្តីពី "ការបំពេញទម្រង់ព័ត៌មានស្នើសុំឥណទានរបស់ស្ថាប័នហិរញ្ញវត្ថុពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន និងសង្គមក្រោមក្របខណ្ឌគម្រោង ACSEP ទំព័រទី៩
- ចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ទំព័រទី៩
- កិច្ចប្រជុំលើការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ទំព័រទី៩
- កម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៣" ទំព័រទី១០

  ការទទួលការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការនៅក្នុងវិស័យបរធនបាលកិច្ច ទំព័រទី១១
- ការផ្តល់អាជ្ញាបណ្ណពីនិយ័តករបរធនបាលកិច្ចធ្វើជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច ទំព័រទី១២
- ការផ្តល់អាជ្ញាបណ្ណបរធនបាលរូបវន្តបុគ្គលឯករាជ្យក្នុងវិស័យបរធនបាលកិច្ច ទំព័រទី១៣
- ការផ្តល់បណ្ណសរសើរ និងពាន ជាធនាគារឆ្នើម ជាប្រតិបត្តិករបរធន-បាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ចដែលបានចុះបញ្ជីបរធនបាលកិច្ចច្រើនជាងគេក្នុងឆ្នាំ២០២២ ទំព័រទី១៣
- ការផ្តល់បណ្ណសរសើរ និងពាន ក្នុងកម្មវិធីវេទិកាបរធនបាលកិច្ច ទំព័រទី១៤
- កិច្ចពិភាក្សាស្តីពី÷ "សុខដុមនីយកម្មនៃក្របខណ្ឌគតិយុត្តក្នុងវិស័យបរធនបាលកិច្ច" ទំព័រទី១៤
- កិច្ចពិភាក្សាស្តីពី÷ "កាលានុវត្តភាពនៃប្រតិបត្តិការបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ទំព័រទី១៥
- កិច្ចពិភាក្សាស្តីពី÷ "កិច្ចគាំពារអតិថិជន និងប្រតិបត្តិការសេវារក្សាទុក/រក្សាសុវត្ថិភាព (Escrow Services) ក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ទំព័រទី១៦




អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចពិភាក្សាជាមួយក្រុមហ៊ុន Shepherd TechFin

នារសៀលថ្ងៃចន្ទ ១រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃ **ន.ប.ធ.**, **លោក ហាយ សុវណ្ណា** ប្រធាននាយកដ្ឋានស្តីទីនៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច និងក្រុមការងារទទួលបន្ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech), បានទទួលជួបជាមួយក្រុមហ៊ុន Shepherd TechFin ដែលជាក្រុមហ៊ុនជំនាញបច្ចេកវិទ្យាផ្នែកហិរញ្ញវត្ថុ។ តំណាងក្រុមហ៊ុន បានចែករំលែកបទពិសោធន៍ និងចំណេះដឹងបច្ចេកវិទ្យាផ្នែកហិរញ្ញវត្ថុ ដែលធ្លាប់បានអនុវត្តពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ចនៅក្នុងវិស័យបរធនបាលកិច្ចសម្រាប់ក្រុមហ៊ុនបរធនបាល បរធនបាលទាយក (ម្ចាស់ទ្រព្យសម្បត្តិ/មូលនិធិ) និងអត្ថគាហកៈ (អ្នកទទួលផលប្រយោជន៍បរធនបាលកិច្ច) ដែលក្នុងនោះរួមមាន៖ ដំណើរការបច្ចេកទេសនៃការចុះបញ្ជីបរធនបាលកិច្ច ការពិនិត្យព័ត៌មាន និងការធ្វើរបាយការណ៍ជាដើម តាមរយៈនវានុវត្តន៍ព័ត៌មានវិទ្យា។





រូបភាពកិច្ចពិភាក្សាជាមួយក្រុមហ៊ុន Shepherd TechFin ដែលជាក្រុមហ៊ុនជំនាញបច្ចេកវិទ្យាផ្នែកហិរញ្ញវត្ថុ។

## ថ្នាក់ដឹកនាំ ន.ប.ធ. បានពាំនាំយកថវិកាដែលជាការបរិច្ចាគ ប្រគល់ជូនមូលនិធិគន្ធបុប្ផាកម្ពុជា

នាព្រឹកថ្ងៃអង្គារ ២រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃ **ន.ប.ធ.**, **លោក យុន រ៉ាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ, **និង លោក ហាយ សុវណ្ណា** ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីបរធនបរធនបាលកិច្ច បានពាំនាំយកថវិកាដែលជាការបរិច្ចាគពីថ្នាក់ដឹកនាំ និងមន្ត្រីនៃ **ន.ប.ធ.** ប្រគល់ជូនមូលនិធិគន្ធបុប្ផាកម្ពុជា ចំនួន ១១,៣៨៥,០០០ រៀល (ដប់មួយលានបីរយប៉ែតសិបប្រាំពាន់រៀលគត់) ដើម្បីចូលរួមចំណែកក្នុងការជួយសង្គ្រោះជីវិតកុមារកម្ពុជា និងធានានិរន្តរភាពនៃកិច្ចដំណើរការរបស់មន្ទីរពេទ្យគន្ធបុប្ផាកម្ពុជា។

សូមបញ្ជាក់ផងដែរថា មូលនិធិគន្ធបុប្ផាកម្ពុជា ត្រូវបានចុះបញ្ជីជាបរធនបាលកិច្ចសាធារណៈនៅនិយ័តករបរធនបាលកិច្ច ដោយអនុលោមតាមច្បាប់ស្តីពីបរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។



រូបភាពថ្នាក់ដឹកនាំ **ន.ប.ធ.** បានពាំនាំយកថវិកាដែលជាការបរិច្ចាគ ប្រគល់ជូនមូលនិធិគន្ធបុប្ផាកម្ពុជា។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកាឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ)

នាព្រឹកថ្ងៃអង្គារ ២រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណី សាគល**អគ្គនាយករងនៃ **ន.ប.ធ.** និង**លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅបានអញ្ជើញចូលរួមកិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកាឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ នៅទីស្តីការ **កសហវ** ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ។





រូបភាពកិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកាឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែមករា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៣

នាព្រឹកថ្ងៃអង្គារ ២រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៣ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែមករា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៣ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពីប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យនិងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានទាំងពីរ។ នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមអគ្គនាយករងបានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែមករា ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងនិងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានទាំងពីរ និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាពកិច្ចប្រជុំបូកសរុបការងារប្រចាំខែមករា ឆ្នាំ២០២៣ និងទិសដៅការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៣ ដឹកនាំដោយ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំពិភាក្សាផ្ទៃក្នុងអំពីការធ្វើបច្ចុប្បន្នភាពឯកសារគោលការណ៍ប្រតិបត្តិទូទៅផ្នែកឥណទាន (GoG) និងនីតិវិធីប្រតិបត្តិមូលនិធិធានាឥណទាន (CGF account)

នាព្រឹកថ្ងៃព្រហស្បតិ៍ ៤រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាពទី១ (PIU 1) បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងអំពីការធ្វើបច្ចុប្បន្នភាពឯកសាគោលការណ៍ប្រតិបត្តិទូទៅផ្នែកឥណទាន (GoG) និងនីតិវិធីប្រតិបត្តិមូលនិធិធានាឥណទាន (CGF account) បន្ទាប់ពីទទួលបានធាតុចូលពីការចុះបេសកកម្មជួបពិភាក្សាផ្ទាល់ជាមួយស្ថាប័នហិរញ្ញវត្ថុ (PFIs), សាជីវកម្មធានាឥណទានកម្ពុជា (CGCC) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមដោយ លោក/កញ្ញា ប្រធានផ្នែកប្រតិបត្តិការ, ប្រធានផ្នែកលទ្ធកម្ម, ប្រធានផ្នែកគណនេយ្យនិងហិរញ្ញវត្ថុ, ប្រធានផ្នែករដ្ឋបាលនិងគាំទ្រទូទៅ, ទីប្រឹក្សាជាតិសម្រាប់គម្រោង ACSEP-PIU1 និងលោក/លោកស្រី ដែលជាសមាជិកក្រុមការងារអនុវត្តគម្រោង ACSEP-PIU1។



រូបភាពកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងអំពីការធ្វើបច្ចុប្បន្នភាពឯកសាគោលការណ៍ប្រតិបត្តិទូទៅផ្នែកឥណទាន (GoG) និងនីតិវិធីប្រតិបត្តិមូលនិធិធានាឥណទាន (CGF account) ។

## កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

នារសៀលថ្ងៃអង្គារ ៩រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ**២០២៣ ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** និង **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការីបានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៤ និងឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។





រូបភាពកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## កម្មវិធីពិធីផ្សព្វផ្សាយ "ចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០៣០"

នាព្រឹកថ្ងៃពុធ ១០រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោក ប៉ុ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងសហការីបានអញ្ជើញចូលរួមពិធីផ្សព្វផ្សាយ "ចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០៣០"

ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក-សមាជិកា នៃក្រុមការងាររៀបចំចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កម្មវិធីនេះត្រូវបានប្រព្រឹត្តទៅនៅសណ្ឋាគារ ឡឺរ៉ូយ៉ាល់ ភ្នំពេញ។







រូបភាពកម្មវិធីពិធីផ្សព្វផ្សាយ "ចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០៣០" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន។

## កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករ

នារសៀលថ្ងៃព្រហស្បតិ៍ ១១រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **កញ្ញា ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច និងមន្ត្រីជំនាញបានចូលរួមកិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី "អាជីវកម្មនិងសេវាកម្មអចលនវត្ថុ" តាមប្រព័ន្ធអនឡាញ Zoom។




រូបភាពកិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម រស់ សីលវ៉ា។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច"

នាព្រឹកថ្ងៃសុក្រ ១២រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) សហការជាមួយរដ្ឋបាលខេត្តព្រះសីហនុបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" នៅសណ្ឋាគារ ឆ្នេរសុខា ខេត្តព្រះសីហនុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និង **លោកស្រី ហៀក ហ៊ីមុល្លី** អភិបាលរង នៃគណៈអភិបាលខេត្តព្រះសីហនុ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម គួច ចំរើន** អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ។

សិក្ខាសាលាផ្សព្វផ្សាយនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងបន្ថែមឱ្យបានកាន់តែទូលំទូលាយដល់សាធារណជន ក៏ដូចជាភាគីពាក់ព័ន្ធដទៃទៀត ថាអ្វីជាបរធនបាលកិច្ច? បរធនបាលកិច្ចមានយន្តការនិងប្រតិបត្តិការ

សាលាផ្សព្វផ្សាយនេះ ក៏បានរំលេចផងដែរអំពីតួនាទី និងសារសំខាន់របស់យន្តការបរធនបាលកិច្ច ក្នុងការបង្កើត និងបង្កើនទំនុកចិត្ត ក៏ដូចជាទាក់ទាញការវិនិយោគបន្ថែម ជាពិសេសចូលរួមចំណែកជំរុញដំណើរការអភិវឌ្ឍន៍គម្រោងធុរកិច្ចនានាក្នុងខេត្តព្រះសីហនុ ក្នុងកម្រិតពាក់ព័ន្ធណាមួយតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងក្នុងក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

សិក្ខាសាលាផ្សព្វផ្សាយនេះ ក៏មានអ្នកចូលរួមសរុបប្រហែល ១០០ រូបផងដែរ ដែលជាថ្នាក់ដឹកនាំ និងតំណាងអញ្ជើញមកពីស្ថាប័នមន្ទីរ អង្គភាពនានានៃរដ្ឋបាលខេត្តព្រះសីហនុ, សមាជិក-សមាជិកានៃសភាពាណិជ្ជកម្ម, សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា, សមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា, សមាគមសហគ្រិនវ័យក្មេងកម្ពុជា, សមាគមអ្នកអភិវឌ្ឍន៍លំនៅឋាន, និងសមាគមធុរកិច្ចពាក់ព័ន្ធ និងតំណាងក្រុមហ៊ុនបរធនបាល និងប្រតិបត្តិករបរធនបាល ដែលទទួលបានអាជ្ញាបណ្ណ និងការអនុញ្ញាតពី **ន.ប.ធ.**។







រូបភាពសិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ ន.ប.ធ. ។

## កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារឆ្នាំ២០២២ និងទិសដៅការងារបន្ត" របស់ ន.ប.ធ

នារសៀលថ្ងៃសុក្រ ១២រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនគារ (**អ.ស.ហ.**), និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំ "កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារឆ្នាំ២០២២ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** និង **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយឯកឧត្តមអគ្គនាយករង និងប្រធាននាយកដ្ឋាននៃ **ន.ប.ធ.** នៅសណ្ឋាគារឆ្នេរសុខា (Sokha Beach) ខេត្តព្រះសីហនុ។

នៅក្នុងកិច្ចប្រជុំនេះ មានការធ្វើបទ បង្ហាញពីគ្រប់នាយកដ្ឋាននៃ **ន.ប.ធ.** អំពីសមិទ្ធផលការងារក្នុងឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ ព្រមទាំងមានការ ពិភាក្សាយ៉ាងផុសផុលក្នុងកម្រិតមន្ត្រី និងថ្នាក់ ដឹកនាំរបស់ **ន.ប.ធ.** លើចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម កាលានុវត្តភាព និងដំណោះស្រាយ ដែលបានអនុវត្តកន្លងមក និងលើកឡើងនូវវិធីសាស្ត្រ ដើម្បីត្រៀមខ្លួនក្នុងការអនុវត្តការងារនៅឆ្នាំបន្ទាប់ឱ្យកាន់តែប្រសើរ។ មុនប្រកាសបិទនៃកិច្ចប្រជុំនេះ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** បានវាយតម្លៃខ្ពស់ដល់មន្ត្រី និងថ្នាក់ដឹកនាំនៃ **ន.ប.ធ.** ដែលបានខិតខំប្រឹងប្រែងរហូតសម្រេចបានលទ្ធផលការងារគួរជាទីមោទនភាព។

កិច្ចប្រជុំត្រូវបានបញ្ចប់នៅវេលាម៉ោង ១៧:៣០ នាទីរសៀល ប្រកបដោយផ្លែផ្កា និងស្មារតីមោះមុតខ្ពស់ក្នុងការបំពេញការងារតាមផែនការឆ្នាំបន្ទាប់។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888





រូបភាពកិច្ចប្រជុំបូកសរុបសមិទ្ធផលការងារឆ្នាំ២០២២ និងទិសដៅការងារបន្ត” របស់ ន.ប.ធ. ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** ។

## សិក្ខាសាលាស្តីពី “ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា”

នាព្រឹកថ្ងៃចន្ទ ១កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងវិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី “ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច, **លោកបណ្ឌិត ផុន ណារិន** នាយក នៃវិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា, នៅវិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅវិទ្យាស្ថាន អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។

កម្មវិធីនេះ មានការអញ្ជើញចូលរួមពីលោក លោកស្រីជាបរធនបាលនៃអង្គការមូលនិធិអេស៊ីលីដា-ចាឌីនសម្រាប់ការអប់រំ, តំណាងក្រុមបរធនបាលនៃបរធនបាលកិច្ចហិរញ្ញវត្ថុអេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់, ថ្នាក់ដឹកនាំជាន់ខ្ពស់, សាស្ត្រាចារ្យ និងនិស្សិត នៃវិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា ដែលមានចំនួនសរុបប្រមាណ ១៧០ រូប។ កម្មវិធីត្រូវបានបញ្ចប់ទៅដោយភាពរលូន និងប្រកបដោយផ្លែផ្កា ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល។



រូបភាពសិក្ខាសាលាស្តីពី “ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច។

## កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២២ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ: ដំណាក់កាលទី៣ ប្លុក២ (PFM-TWG)

នាព្រឹកថ្ងៃពុធ ៣កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តមអគ្គនាយករង **ណី សាគល**, **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ និងមន្ត្រីជំនាញការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ នៃ **ន.ប.ធ.** បានចូលរួមកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២២នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ: ដំណាក់កាលទី៣ ប្លុក២ (PFM-TWG) ក្រោមអធិបតីភាពដ៏



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយមានការចូលរួមពីឯកឧត្តមរដ្ឋលេខាធិការ ឯកឧត្តមប្រតិភូ ឯកឧត្តមអគ្គនាយក ថ្នាក់ដឹកនាំ និងតំណាងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។



រូបភាពកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២២ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ បូក២ (PFM-TWG)។





រូបភាពសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។

## សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នាព្រឹកថ្ងៃព្រហស្បតិ៍ ៤កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេង យល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច និង **លោក យិត សុវឌ្ឍ** សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ សម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។

កម្មវិធីនេះ មានការអញ្ជើញចូលរួមពីលោកសាស្ត្រាចារ្យជាថ្នាក់គ្រប់គ្រងជាន់ខ្ពស់, សាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានចំនួនសរុបប្រមាណ ២១០ រូប។

## កិច្ចប្រជុំផ្សព្វផ្សាយសារាចរស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ និងផ្សព្វផ្សាយគម្រោងថវិការបស់ ន.ប.ធ. ឆ្នាំ២០២៣

នាព្រឹកថ្ងៃព្រហស្បតិ៍ ៤កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ **ឯកឧត្តម ណឹ សកល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយសារាចរស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ និងផ្សព្វផ្សាយគម្រោងថវិការបស់ **ន.ប.ធ.** ឆ្នាំ២០២៣ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាន៖ នាយកដ្ឋានកិច្ចការទូទៅ, នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច, នាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ។



រូបភាពកិច្ចប្រជុំផ្សព្វផ្សាយសារាចរស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ និងផ្សព្វផ្សាយគម្រោងថវិការបស់ ន.ប.ធ. ឆ្នាំ២០២៣ ដឹកនាំដោយ **ឯកឧត្តម ណឹ សកល**។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## វគ្គបណ្តុះបណ្តាលស្តីពី "ការបំពេញទម្រង់ព័ត៌មានស្នើសុំឥណទានរបស់ស្ថាប័នហិរញ្ញវត្ថុពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន និងសង្គមក្រោមក្របខណ្ឌគម្រោង ACSEP

នាព្រឹកថ្ងៃសុក្រ ៥កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្មសម្រាប់សមាសភាគទី១ (ACSEP PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**ក.ស.ហ.វ.**) បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការបំពេញទម្រង់ព័ត៌មានស្នើសុំឥណទានរបស់ស្ថាប័នហិរញ្ញវត្ថុពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន និងសង្គមក្រោមក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្មសម្រាប់សមាសភាគទី១" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោង ACSEP PIU1 នៅសណ្ឋាគារ សុខា រាជធានីភ្នំពេញ។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីបណ្តុះបណ្តាលដល់ក្រុមការងារនៃធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា ដែលជាស្ថាប័នហិរញ្ញវត្ថុដៃគូក្នុងគម្រោង ACSEP PIU1 ពីនីតិវិធីលម្អិត និងការបំពេញទម្រង់ព័ត៌មានស្នើសុំឥណទានរបស់ស្ថាប័នហិរញ្ញវត្ថុពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន និងសង្គមក្រោមក្របខណ្ឌគម្រោង ACSEP PIU1។

សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនេះ មានការចូលរួមពីសមាជិកនិងទីប្រឹក្សារបស់ ACSEP PIU1 និងក្រុមការងារមកពីធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាពវគ្គបណ្តុះបណ្តាលស្តីពី "ការបំពេញទម្រង់ព័ត៌មានស្នើសុំឥណទានរបស់ស្ថាប័នហិរញ្ញវត្ថុពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន និងសង្គមក្រោមក្របខណ្ឌគម្រោង ACSEP។

## ចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃព្រហស្បតិ៍ ៥កើតខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល (២០២៣-២០២៥) របស់អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** អនុប្រធាន **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។



រូបភាពចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) ធនាគារ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម រស់ សីលវ៉ា។

## កិច្ចប្រជុំលើការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា

នាព្រឹកថ្ងៃចន្ទ ៨កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា បានចូលរួមកិច្ចប្រជុំលើការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា។

កិច្ចប្រជុំនេះ រៀបចំឡើងក្នុងគោលបំណងដើម្បីរាយការណ៍ពីវឌ្ឍនភាពការងារមុននឹងឈានដល់ការបញ្ចប់សេចក្តីព្រាងដំបូង និងរាយការណ៍លទ្ធផលនៃការសិក្សាវាយតម្លៃលើវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជារបស់ទីប្រឹក្សាជំនាញពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) តាមរយៈប្រព័ន្ធវីដេអូពីចម្ងាយ Zoom។




រូបភាពកិច្ចប្រជុំលើការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា**។

## កម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៣"

កាលពីថ្ងៃអង្គារ ៩កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៣" ក្រោមប្រធានបទស្តីពី "ក្របខណ្ឌបទប្បញ្ញត្តិ ឧត្តមានុវត្តន៍ និងកាលានុវត្តភាព" ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារ ភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**។

វេទិកាបរធនបាលកិច្ចឆ្នាំ ២០២៣ នេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយពីវឌ្ឍនភាពនៃកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅកម្ពុជា ទៅកាន់គ្រប់តួអង្គពាក់ព័ន្ធនៅក្នុងវិស័យបរធនបាលកិច្ចរួមមានប្រតិបត្តិករក្នុងទីផ្សារ ក្រុមហ៊ុនដែលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច វិនិយោគិនសក្តានុពល និងសមាគមធុរកិច្ចសក្តានុពលនៅក្នុងប្រទេស និងប្រកាសជាផ្លូវការអំពីអត្ថិភាពនៃទីផ្សារបរធនបាលកិច្ចជាមួយប្រតិបត្តិការពេញលេញ នៅប្រទេសកម្ពុជាចាប់ពីពេលនេះតទៅ ពោលមានន័យថា នៅប្រទេសកម្ពុជាយើងចាប់ពីពេលតទៅ វិស័យបរធនបាលកិច្ច ក៏ដូចជាទីផ្សារបរធនបាលកិច្ចដែលបានចាប់ផ្តើមដំណើរការពេញលេញរបស់ខ្លួន ដោយមាននិយ័តករត្រូវបានបង្កើតឡើងដោយច្បាប់ មានទីផ្សារ មានប្រតិបត្តិករនិងតួអង្គពាក់ព័ន្ធដែលផ្តល់សេវាក្នុងទីផ្សារបរធនបាលកិច្ច មានប្រភេទផលិតផលនិងសេវាកម្មពាក់ព័ន្ធ មានលិខិតបែបបទ បទដ្ឋាន ដើម្បីដំណើរការគ្រប់គ្រងនិងត្រួតពិនិត្យទីផ្សារបរធនបាលកិច្ច ក្នុងវេទិកាបរធនបាលកិច្ចឆ្នាំ២០២៣ នៅសណ្ឋាគារភ្នំពេញ ចំពោះមុខអ្នកចូលរួមប្រមាណ ២០០ នាក់ ដែលតំណាងឱ្យស្ថាប័ន និងក្រុមហ៊ុនពាក់ព័ន្ធ ជាតិ និងអន្តរជាតិជាង ១០០ ស្ថាប័ន ដែលមកពីវិស័យហិរញ្ញវត្ថុ វិស័យអចលនទ្រព្យ និងវិស័យច្បាប់។ល។

កម្មវិធីនេះក៏ផ្តោតជាសំខាន់ទៅលើបទបង្ហាញ និងកិច្ចពិភាក្សាអំពីក្របខណ្ឌច្បាប់ ប្រភេទប្រតិបត្តិការបរធនបាលកិច្ចសក្តានុពល និងកាលានុវត្តភាពក្នុងទីផ្សារកម្ពុជា ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមប្រតិភូអគ្គនាយកនិយ័តករមូលបត្រកម្ពុជា ឯកឧត្តមអគ្គនាយកនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ លោក លោកស្រីជាតំណាងប្រតិបត្តិករបរធនបាល ដែលមានជំនាញនិងបទពិសោធច្រើនឆ្នាំ និងមានភ្ញៀវជាតិមកពីស្ថាប័នរដ្ឋ វិស័យឯកជន និងភ្ញៀវអន្តរជាតិអញ្ជើញមកពីបរទេសផងដែរ។








រូបភាពកម្មវិធី "វេទិកាបរធនបាលកិច្ច ឆ្នាំ២០២៣" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម មី វ៉ាន់។

## ការទទួលការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការនៅក្នុងវិស័យបរធនបាលកិច្ច

ក្រុមហ៊ុនចំនួន ៦ ដែលទទួលបានអាជ្ញាបណ្ណ និងការទទួលការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការនៅក្នុងវិស័យបរធនបាលកិច្ចក្នុងវេទិកាបរធនបាលកិច្ចឆ្នាំ២០២៣ នាព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ចបានប្រកាសឈ្មោះក្រុមហ៊ុនចំនួន៦ ដែលទទួលបានការអនុញ្ញាតពីនិយ័តករបរធនបាលកិច្ច ឱ្យធ្វើប្រតិបត្តិការនៅក្នុងវិស័យបរធនបាលកិច្ចនៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីក្រុមហ៊ុនទាំងនោះបានបំពេញតាមលក្ខខណ្ឌតម្រូវគ្រប់គ្រាន់ តាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានក្នុងវិស័យបរធនបាលកិច្ច។ ក្រុមហ៊ុនទាំង ៦ ដែលទទួលបានការអនុញ្ញាតនោះ រួមមានក្រុមហ៊ុន កាណា ត្រាស ឯ.ក អនុញ្ញាតឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម និងបរធនបាលកិច្ចសង្គម, ក្រុមហ៊ុន ហ្វីលីព ត្រាសធី (ខេមបូឌា) ឯ.ក អនុញ្ញាតឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម បរធនបាលកិច្ចសង្គម និងបរធនបាលកិច្ចបុគ្គល, ក្រុមហ៊ុន ហាវ ត្រាស ឃៃភីថល អ៊ិនវេសម៉ិន ឯ.ក អនុញ្ញាតឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចសាធារណៈ បរធនបាលកិច្ចពាណិជ្ជកម្ម បរធនបាលកិច្ចសង្គម និងបរធនបាលកិច្ចបុគ្គល, ក្រុមហ៊ុន អេសជី ថប ឯ.ក អនុញ្ញាតឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម,ក្រុមហ៊ុន ស្រ្តងហូល ត្រាសធី ឯ.ក អនុញ្ញាតឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម និងបរធនបាលកិច្ចបុគ្គល និងក្រុមហ៊ុន ហ្រ្គេន កាថេ អ៊ិនវេសម៉ិន ត្រាស អនុញ្ញាតឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម និងបរធនបាលកិច្ចបុគ្គល។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888














រូបភាពការទទួលការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការនៅក្នុងវិស័យបរធនបាលកិច្ច ក្នុងកម្មវិធីវេទិកាបរធនបាលកិច្ច កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

## ការផ្តល់អាជ្ញាបណ្ណពីនិយ័តករបរធនបាលកិច្ចធ្វើជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច

ធនាគារឈានមុខគេនៅកម្ពុជាចំនួន២ ទទួលបានអាជ្ញាបណ្ណពីនិយ័តករបរធនបាលកិច្ចធ្វើជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច សម្រាប់ប្រតិបត្តិការបរធនបាលកិច្ច៖ ក្នុងវេទិកាបរធនបាលកិច្ចឆ្នាំ២០២៣ នាព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ចបានប្រកាសឈ្មោះធនាគារឈានមុខគេនៅកម្ពុជាចំនួន ២ ដែលទទួលបានអាជ្ញាបណ្ណឱ្យធ្វើជាប្រតិបត្តិករបរធនបាលសម្រាប់ធ្វើប្រតិបត្តិការបរធនបាលកិច្ចផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក ក្នុងវិស័យបរធនបាលកិច្ច បន្ទាប់ពីធនាគារធំៗទាំង ២ បានបំពេញតាមលក្ខខណ្ឌតម្រូវគ្រប់គ្រាន់ តាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានក្នុងវិស័យបរធនបាលកិច្ច។ ធនាគារទាំង២ រួមមាន ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលទទួលបានការអនុញ្ញាតជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ធ្វើប្រតិបត្តិការបរធនបាលកិច្ចសាធារណៈ បរធនបាលកិច្ចហិរញ្ញវត្ថុ បរធនបាលកិច្ចពាណិជ្ជកម្ម បរធនបាលកិច្ចសង្គម និងបរធន-បាលកិច្ចបុគ្គល និងធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ (ABA) ដែលទទួលបានអាជ្ញាបណ្ណជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក សម្រាប់ធ្វើប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម។






រូបភាពការផ្តល់អាជ្ញាបណ្ណពីនិយ័តករបរធនបាលកិច្ចធ្វើជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច ក្នុងកម្មវិធីវេទិកាបរធនបាលកិច្ច កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

## ការផ្តល់អាជ្ញាបណ្ណបរធនបាលរូបវន្តបុគ្គលឯករាជ្យក្នុងវិស័យបរធនបាលកិច្ច

មេធាវីចំនួន ២ រូបនៃការិយាល័យពីរផ្សេងគ្នា មានគុណវុឌ្ឍិគ្រប់គ្រាន់ ដោយទទួលបានអាជ្ញាបណ្ណបរធនបាលរូបវន្តបុគ្គលឯករាជ្យក្នុងវិស័យបរធនបាលកិច្ច៖ ក្នុងវេទិកាបរធនបាលកិច្ចឆ្នាំ២០២៣ នាព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានប្រកាសពីមេធាវី ២ រូប នៃការិយាល័យមេធាវីផ្សេងគ្នា ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ ទទួលបានអាជ្ញាបណ្ណបរធនបាលរូបវន្តបុគ្គលឯករាជ្យក្នុងវិស័យបរធនបាលកិច្ច ដែលអាចធ្វើអាជីវកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានក្នុងវិស័យបរធនបាលកិច្ច។ **មេធាវី អ៊ឹម ពិសី** ប្រធានការិយាល័យមេធាវី វីចេង និង **មេធាវី រស់ មុនិន្ទ:** អគ្គនាយកនៃក្រុមហ៊ុនមេធាវី ខេមជីន ត្រូវបាន **ន.ប.ធ.** សម្រេចផ្តល់អាជ្ញាបណ្ណឱ្យបន្ទាប់ពីមេធាវីទាំង២ រូប បានបំពេញតាមលក្ខខណ្ឌតម្រូវគ្រប់គ្រាន់ តាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានក្នុងវិស័យបរធនបាលកិច្ច។







រូបភាពការផ្តល់អាជ្ញាបណ្ណបរធនបាលរូបវន្តបុគ្គលឯករាជ្យក្នុងវិស័យបរធនបាលកិច្ច ក្នុងកម្មវិធីវេទិកាបរធនបាលកិច្ច កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

## ការផ្តល់បណ្ណសរសើរ និងពាន ជាធនាគារឆ្នើម ជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច ដែលបានចុះបញ្ជីបរធនបាលកិច្ចច្រើនជាងគេក្នុងឆ្នាំ២០២២




ធនាគារ អេស៊ីលីដា ភីអិលស៊ី ទទួលបានបណ្ណសរសើរ និងពាន ជាធនាគារឆ្នើម ជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច ដែលបានចុះបញ្ជីបរធនបាលកិច្ចច្រើនជាងគេក្នុងឆ្នាំ២០២២៖ ក្នុងវេទិកាបរធនបាលកិច្ចឆ្នាំ២០២៣ នាព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានផ្តល់បណ្ណសរសើរនិងពានឆ្នើមដល់ ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច ដែលបានចុះបញ្ជីបរធនបាលកិច្ចច្រើនជាងគេក្នុងឆ្នាំ២០២២ បន្ទាប់ពីធនាគារនេះទទួលបានការអនុញ្ញាតពី **ន.ប.ធ.** ជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាពឬសេវារក្សាទុក សម្រាប់ធ្វើប្រតិបត្តិការបរធនបាលកិច្ចសាធារណៈ បរធនបាលកិច្ចហិរញ្ញវត្ថុ បរធនបាលកិច្ចពាណិជ្ជកម្ម បរធន-បាលកិច្ចសង្គម និងបរធនបាលកិច្ចបុគ្គល ធនាគារ អេស៊ីលីដា បានចុះបញ្ជី ប្រតិបត្តិការបរធនបាលកិច្ចផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក នៅ **ន.ប.ធ.** ច្រើនជាងគេក្នុងឆ្នាំ២០២២។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ការផ្តល់បណ្ណសរសើរ និងពាន ក្នុងកម្មវិធីវេទិកាបរធនបាលកិច្ច

ក្នុងវេទិកាបរធនបាលកិច្ចឆ្នាំ២០២៣ នាព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានផ្តល់បណ្ណសរសើរ និងពានដល់៖

- ក្រុមបរធនបាលនៃបរធនបាលកិច្ចហិរញ្ញវត្ថុ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ជាក្រុមបរធនបាលដែលមានការគ្រប់គ្រងចាត់ចែង និងរក្សាទុកបរធនបាលកិច្ចល្អប្រសើរ និងមានកំណើនទំហំបរធនខ្ពស់
- ក្រុមហ៊ុន កាណា ត្រាស ឯ.ក ជាក្រុមហ៊ុនបរធនបាលដែលឈានមុខក្នុងការបង្កើត និងចុះបញ្ជីបរធនបាលកិច្ចច្រើនជាងគេ
- សារព័ត៌មាន ខេមបូឌាមីស, អង្គភាពព័ត៌មាន Fresh News, ទូរទស្សន៍ជាតិកម្ពុជា (**ទ.ទ.ក.**) និងទូរទស្សន៍បាយ័ន អង្គភាពសារព័ត៌មាន ឈានមុខគេក្នុងការផ្សព្វផ្សាយព័ត៌មានពីវិស័យបរធនបាលកិច្ចទៅកាន់សាធារណជនប្រចាំឆ្នាំ២០២២។




រូបភាពការផ្តល់បណ្ណសរសើរ និងពាន ក្នុងកម្មវិធីវេទិកាបរធនបាលកិច្ច កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

## កិច្ចពិភាក្សាស្តីពី៖ "សុខដុមនីយកម្មនៃក្របខណ្ឌគតិយុត្តក្នុងវិស័យបរធនបាលកិច្ច"

តាមរយៈវេទិកាបរធនបាលកិច្ចឆ្នាំ២០២៣ ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារភ្នំពេញ កាលពីព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ នៅក្នុងវគ្គពិភាក្សាស្តីពី៖ "សុខដុមនីយកម្មនៃក្របខណ្ឌគតិយុត្តក្នុងវិស័យបរធនបាលកិច្ច" ឯកឧត្តម សុខ ដារ៉ា អគ្គនាយក នៃនិយ័តករបរធន-បាលកិច្ច **ឯកឧត្តម ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃនិយ័តករមូលបត្រកម្ពុជា និង **ឯកឧត្តម ជូ វណ្ណៈ** អគ្គនាយក នៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ ជាវាគ្មិនកិត្តិយស បានពិភាក្សាអំពីភាពប្រទាក់ក្រឡា ការគាំទ្រគ្នា និងអន្តរទំនាក់ទំនងរវាងវិស័យបរធនបាលកិច្ច វិស័យមូលបត្រ និងវិស័យអាជីវកម្មអចលនវត្ថុ។ កិច្ចពិភាក្សាក៏បានគូសរំលេចពីសារសំខាន់នៃប្រតិបត្តិការបរធនបាលកិច្ចក្នុងកិច្ចជំរុញការអភិវឌ្ឍអនុវិស័យទាំងពីរ ហើយគំនិតផ្តួចផ្តើមថ្មីៗនៅក្នុងវិស័យមូលបត្រ ដូចជាការបោះផ្សាយឯកតាមូលនិធិគម្រោងវិនិយោគរួម, ការរៀបចំស្នើឡើងនូវសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិដើម្បីជំរុញកា រអភិវឌ្ឍ និងការគ្រប់គ្រងវិស័យអចលនទ្រព្យ នឹងក្លាយជាលំហរកាលានុវត្តភាពថ្មីបន្ថែមទៀតសម្រាប់ប្រតិបត្តិការបរធនបាលកិច្ចនៅកម្ពុជាផងដែរ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




រូបភាពកិច្ចពិភាក្សាស្តីពីៈ "សុខដុមនីយកម្មនៃក្របខណ្ឌគតិយុត្តក្នុងវិស័យបរធនបាលកិច្ច" ក្នុងកម្មវិធីវេទិកាបរធនបាលកិច្ច កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

## កិច្ចពិភាក្សាស្តីពីៈ "កាលានុវត្តភាពនៃប្រតិបត្តិការបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

តាមរយៈវគ្គពិភាក្សាស្តីពីៈ "កាលានុវត្តភាពនៃប្រតិបត្តិការបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" នៃវេទិកាបរធនបាលកិច្ចឆ្នាំ២០២៣ ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារភ្នំពេញ កាលពីព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ បានបង្ហាញសក្តានុពលនៃប្រតិបត្តិការបរធនបាលកិច្ចច្រើនប្រភេទនៅប្រទេសកម្ពុជា មានដូចជាៈ បរធនបាលកិច្ចគ្រួសារ, បរធនបាលកិច្ចអចលនទ្រព្យ, បរធនបាលកិច្ចធានារ៉ាប់រង និងបរធនបាលកិច្ចផ្សេងទៀត។ បរធន-បាលកិច្ចទាំងនេះ នឹងជួយជំរុញ និងធានានិរន្តរភាពភាពហិរញ្ញវត្ថុគ្រួសារឆ្លងជំនាន់ ក៏ដូចជាការពារហានិភ័យមួយចំនួន និងផ្តល់ការយកចិត្តទុកដាក់ និងក្តីស្រឡាញ់ដល់អ្នកជំនាន់ក្រោយ។

កិច្ចពិភាក្សាមានការអញ្ជើញចូលរួមពីវាគ្មិនជាតិ និងអន្តរជាតិ រួមមានៈ **ឯកឧត្តម ណឹ សាគល** អគ្គនាយករង នៃនិយ័តករបរធនបាលកិច្ច, **កញ្ញា ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ចនៃនិយ័តករបរធនបាលកិច្ច, អ្នកនាង Halyn CHAI ប្រតិបត្តករបរធនបាលកិច្ចនិងអចលនវត្ថុ នៃក្រុមហ៊ុន Phillip Group Singapore, លោក Han CHEN នាយកគ្រប់គ្រងទូទៅ នៃក្រុមហ៊ុន ស្រ្តងហូល ត្រាសធី ឯ.ក, **លោកស្រី ប៊ុត កេវ៉ាឌី** នាយិកាប្រតិបត្តិ នៃហ្វ្រេន កាថេ អ៊ិនវេសម៉ិន ត្រាស (ខេមបូឌា) ម.ក និង **លោក ម៉ឹង សំណាង** នាយកប្រតិបត្តិ នៃក្រុមហ៊ុន ហាវ ត្រាស យែភីថល អ៊ិនវេសម៉ិន ឯ.ក។




រូបភាពកិច្ចពិភាក្សាស្តីពីៈ "កាលានុវត្តភាពនៃប្រតិបត្តិការបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"ក្នុងកម្មវិធីវេទិកាបរធនបាលកិច្ច កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

## កិច្ចពិភាក្សាស្តីពី៖ "កិច្ចគាំពារអតិថិជន និងប្រតិបត្តិការសេវារក្សាទុក/រក្សាសុវត្ថិភាព (Escrow Services) ក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

តាមរយៈកិច្ចពិភាក្សាក្នុងវេទិកាបរធនបាលកិច្ចឆ្នាំ២០២៣ ស្តីពី៖ "កិច្ចគាំពារអតិថិជន និងប្រតិបត្តិការសេវារក្សាទុក/រក្សាសុវត្ថិភាព (Escrow Services) ក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" វាគ្មិនអញ្ជើញមកពីនិយ័តករបរធនបាលកិច្ច, ធនាគារអេស៊ីលីដា ភីអិលស៊ី និងធនាគារវឌ្ឍនៈអាស៊ីចំកាត់បានគូសបញ្ជាក់ពីសារសំខាន់នៃប្រតិបត្តិការសេវារក្សាទុក/រក្សាសុវត្ថិភាព (Escrow Services) ដែលមានអនុលោមភាពតាមច្បាប់ និងចុះបញ្ជីបរធនបាលកិច្ចត្រឹមត្រូវ ដែលរួមមាន៖ ១.អាចជួយការពារហានិភ័យ បង្កើតទំនុកចិត្ត និងបង្កើនសុវត្ថិភាពដល់ ភាគីពាក់ព័ន្ធ និង ២.មានអនុលោមភាព និងការគាំពារដោយច្បាប់ និងមាននិយ័តករធ្វើការតាមដាន និងត្រួតពិនិត្យទៅលើប្រតិបត្តិការនេះ។

សូមបញ្ជាក់ថាសេវារក្សាទុក/រក្សាសុវត្ថិភាព (Escrow Services) សំដៅដល់ប្រតិបត្តិការដែលក្នុងនោះម្ចាស់ទ្រព្យបានប្រគល់ទ្រព្យរបស់ខ្លួនឱ្យទៅធនាគារពាណិជ្ជ ដែលទទួលបានអាជ្ញាបណ្ណ និងការអនុញ្ញាតពី **ន.ប.ធ.** ធ្វើជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាទុក/រក្សាសុវត្ថិភាព (Escrow Services) ដើម្បីរក្សាសុវត្ថិភាព ឬរក្សាទុក តាមរយៈការបង្កើតគណនី Escrow ក្នុងគោលបំណងដើម្បីធ្វើការទូទាត់ ឬប្រគល់ទ្រព្យនោះទៅឱ្យបុគ្គលណាមួយ ក្នុងប្រតិបត្តិការធុរកិច្ច ឬក្នុងប្រតិបត្តិការអចលនទ្រព្យ ឬក្នុងប្រតិបត្តិការវិនិយោគនានា នៅពេលកំណត់ជាក់លាក់ណាមួយតាមលក្ខខណ្ឌដែលបានព្រមព្រៀង។




រូបភាពកិច្ចពិភាក្សាស្តីពី៖ "កិច្ចគាំពារអតិថិជន និងប្រតិបត្តិការសេវារក្សាទុក/រក្សាសុវត្ថិភាព (Escrow Services) ក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្នុងកម្មវិធីវេទិកាបរធនបាលកិច្ច កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888